ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១២៤/១១-ស៊ីង ឆាង ស៊ីន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: វ៉ែន ពៅ
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: រុន សារ៉ាយ

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ស៊ីង ឆាង ស៊ីន**
អាសយដ្ឋាន ៖ ផ្លូវសង់ថ្មី សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៨៥១ ៩៨៦ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក យស ដារ៉ា | បុគ្គលិក |
| ២- កញ្ញា ចាន់ ថាវី | រដ្ឋបាល |
| ៣- កញ្ញា ជឹម ស្រីមុំ | ជំនួយការរដ្ឋបាល |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា**
- **សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន** XING CHANG XIN (CAMBODIA)

អាសយដ្ឋាន ៖ ផ្ទះលេខ ២-៣G ផ្លូវ ២៦ BT ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ២៩៥ ៨៩៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

១- លោក ស៊ាង យ៉ូត មន្ត្រីដោះស្រាយវិវាទ CCAWDU

២- លោក ជឹម យឿង មន្ត្រីដោះស្រាយវិវាទ CCAWDU

៣- លោក ហូ រដ្ឋា ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន XING CHANG XIN (CAMBODIA)

៤- លោក ឈឹម សំអន ហរញ្ញិកសហជីព

៥- លោក លាង ផល្លា ទីប្រឹក្សាសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

ទាមទារសុំឱ្យក្រុមហ៊ុនទទួលយកលោក ហូ រដ្ឋា ជាថ្នាក់ដឹកនាំសហជីពចូលធ្វើការវិញ និងគិតប្រាក់រំលឹកចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ ។ ដោយឡែកភាគីនិយោជកបានបញ្ជាក់ថា មិនអាចទទួលយកលោក ហូ រដ្ឋា ឱ្យចូលធ្វើការវិញបានឡើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជា នឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១០៨៦ កប/អក/វក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១១ (វេលាម៉ោង ០២ និង ០០ នាទី រសៀល) ។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីការទាមទារឱ្យក្រុមហ៊ុនទទួលយកលោក ហូ រដ្ឋា ជាថ្នាក់ដឹកនាំសហជីព ចូល

ធ្វើការវិញ និងគិតប្រាក់រំលឹកចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០១ ចំណុច លើការទាមទារចំនួន ០៤ ចំណុច។

ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ១០៨៦ ក.ប/អក/វ.ក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១១ ។ បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ០១ ចំណុចនេះ នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ០២ និង ០០ នាទី រសៀល ។

ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០១ ចំណុចនេះបន្ថែមទៀត ប៉ុន្តែជាលទ្ធផលពុំទទួលបានការសះជានឹងគ្នាទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទមិនសះចំនួនមួយ ចំណុចខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា លេខ ១៦១/១១ សបក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ គោរពជូនលោកនាយកក្រុមហ៊ុន Xin Chang Xin ស្តីពីការជូនដំណឹងការបោះឆ្នោតបង្កើតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន XING CHANG XIN (CAMBODIA) ។

២- លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា លេខ ១៦១/១១ សបក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ គោរពជូន លោកនាយកក្រុមហ៊ុន Xin Chang Xin ស្តីពីលទ្ធផលបោះឆ្នោតបង្កើតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន XING CHANG XIN (CAMBODIA) ។

៣- លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាលេខ ១៦៥/១១ សបក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១១ គោរពជូន លោកនាយកក្រុមហ៊ុន Xin Chang Xin ស្តីពីលទ្ធផលបោះឆ្នោតបង្កើតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន XING CHANG XIN (CAMBODIA) ។

៤- លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា លេខ ១៦៩/១១ សបក ចុះថ្ងៃទី២៥

ខែកក្កដា ឆ្នាំ២០១១ គោរពជូនលោកនាយកក្រុមហ៊ុន Xin Chang Xin ស្តីពីលទ្ធផលបោះឆ្នោតបង្កើតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន XING CHANG XIN (CAMBODIA) ។

៥- ប័ណ្ណសំគាល់សមាជិកសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ។

៦- សារណាក្រុមហ៊ុន Xin Chang Xin លេខ ១៣០/១១ ចុះថ្ងៃទី១១ ខែ តុលា ឆ្នាំ២០១១ ។

៧- វិញ្ញាបនប័ត្រសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន XING CHANG XIN (CAMBODIA) ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១-របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ស៊ីងឆាងស៊ីន លេខ ១០៨៦ កប/អក/វក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១។

២-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ស៊ីងឆាងស៊ីន ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១-លិខិតអញ្ជើញនិយោជកចូលរួមសវនាការលេខ ៧០៣ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០១១។

២-លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៧០៤ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ស៊ីង ឆាង ស៊ីន គឺជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់។ ក្រុមហ៊ុននេះ ទើបនឹងចាប់ដំណើរការពីខែកុម្ភៈ ឆ្នាំ២០១១ ដែលមានជួលកម្មករនិយោជិតចំនួនជាង ៥០០ នាក់។
- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គឺជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពនេះទទួលបានបញ្ជិកានៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១។

ចំណុចវិវាទ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកលោក ហូ រដ្ឋា ជាថ្នាក់ដឹកនាំសហជីព ចូលធ្វើការវិញ និងគិតប្រាក់រំលឹកចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ

- លោក ហូ រដ្ឋា បានចាប់ផ្តើមចូលធ្វើការដំបូងដែលមានការងារសាកល្បងចំនួន ២ ខែ ចាប់ពីថ្ងៃទី០៣ ខែមីនា រហូតដល់ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១១ ដោយមានប្រាក់ឈ្នួលគោលចំនួន ៦៤ ដុល្លារអាមេរិក ក្នុង

មួយខែ។ បន្ទាប់មក និយោជកក៏បានបន្តកិច្ចសន្យាដែលមានកំណត់ថិរវេលាចំនួន ៣ ខែបន្តទៀត ដោយគិតចាប់ពីថ្ងៃទី០៣ ខែឧសភា ដល់ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ។

- នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១ និយោជកបានបញ្ចប់កិច្ចសន្យាការងាររបស់គាត់ដោយទូទាត់ប្រាក់ឈ្នួលផ្តាច់កិច្ចសន្យាការងារជូនគាត់ទៅតាមច្បាប់ស្តីពីការងារ។ ហើយលោក ហូ រដ្ឋា ក៏បានទទួលយកប្រាក់ឈ្នួលទូទាត់បញ្ចប់កិច្ចសន្យានោះហើយដែរ។
- ភាគីកម្មករនិយោជិតបានលើកឡើងថា នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ កម្មករនិយោជិតបានរៀបចំបោះឆ្នោតសហជីពលើកទី៣ ដោយមានលោក ហូ រដ្ឋា ជាប់ជាប្រធានសហជីព លោក ស៊ឹម សារ៉ាង ជាប់ជាអនុប្រធាន និងលោក អេន សុខណា ជាប់ជាលេខាសហជីព។ នៅថ្ងៃដដែលនោះ ភាគីកម្មករនិយោជិតបានជូនដំណឹងទៅក្រុមហ៊ុន ស្តីពីលទ្ធផលបោះឆ្នោតសហជីពដែរ ពេលនោះសន្តិសុខក្រុមហ៊ុនទទួល ប៉ុន្តែគាត់ពុំព្រមចុះហត្ថលេខា ដើម្បីបញ្ជាក់ថា បានទទួលទេ។
- ភាគីកម្មករនិយោជិតបានលើកឡើងថា មូលហេតុដែលនិយោជកពុំបន្តកិច្ចសន្យាការងារជូនលោក ហូ រដ្ឋា គឺបណ្តាលមកពីនិយោជកមានការរើសអើងប្រឆាំងនឹងសហជីព។ ពោលគឺ ចាប់តាំងពីពេលដឹងថា លោក ហូ រដ្ឋា ជាប់ឆ្នោតជាប្រធានសហជីពមក។
- ភាគីនិយោជកបានបញ្ជាក់ថា មូលហេតុដែលនិយោជកពុំអាចបន្តកិច្ចសន្យាការងារជូនគាត់ ព្រោះតាមរបាយការណ៍ពីប្រធានក្រុមដេរបានបង្ហាញថា លោក ហូ រដ្ឋា ពុំសូវយកចិត្តទុកដាក់នឹងការងារទេ ការងាររបស់គាត់ពុំល្អ ហើយគាត់ពុំសហការជាមួយក្រុមហ៊ុនទេ។ ម្យ៉ាងទៀត ទាក់ទងទៅនឹងការបញ្ឈប់នេះ និយោជកពុំបានដឹងថា គាត់ជាថ្នាក់ដឹកនាំសហជីពទេ។
- នៅថ្ងៃសវនាការ ភាគីនិយោជកបានសន្យាថា នឹងផ្តល់ឯកសារពាក់ព័ន្ធទៅនឹងការវាយតម្លៃលើលក្ខណៈសម្បត្តិការងាររបស់លោក ហូ រដ្ឋា មកក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ប៉ុន្តែ មកដល់កាលបរិច្ឆេទថ្ងៃកំណត់ ភាគីនិយោជកពុំបានផ្តល់ជូនតាមការសន្យាទេ។
- តាមរយៈសារណាដែលផ្តល់ដោយភាគីកម្មករនិយោជិត បានបង្ហាញពីលទ្ធផលបោះឆ្នោតសហជីពលើកទី៣ ដែលមានកម្មករនិយោជិតចំនួន ៩ នាក់ ជាប់ជាថ្នាក់ដឹកនាំសហជីព និងក្រុមប្រឹក្សាសហជីពនោះ គឺនិយោជកបានបញ្ចប់កិច្ចសន្យាការងារតែលោក ហូ រដ្ឋា ម្នាក់ប៉ុណ្ណោះ។ ចំណែកឯកញ្ញា អេន សុខណា ដែលបានជាប់ជាលេខាធិការសហជីពនោះ បានលាលែងពីការងារដោយខ្លួនឯង។

**ហេតុផលនៃសេចក្តីសម្រេច**

ចំណុចវិវាទ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកលោក ហូ រដ្ឋា ជាថ្នាក់ដឹកនាំសហជីព ចូលធ្វើការវិញ និងគិតប្រាក់រំលឹកចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាលើការទាមទារ ដូចខាងក្រោមនេះ ៖

មាត្រា ៧៣ នៃច្បាប់ការងារឆ្នាំ១៩៩៧ ចែងថា " *កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាត្រូវផុតរលត់តាមធម្មតានូវពេលដល់កាលកំណត់ ...* "។

នៅក្នុងសំណុំរឿងលេខ ១០០/០៧-ហូយៀ ខេមបូឌា ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា " *ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាត្រូវផុតរលត់ជាស្វ័យប្រវត្តិនៅពេលដល់កាលកំណត់។ មានន័យថា កាតព្វកិច្ចរបស់ភាគីនិយោជក និងកម្មករនិយោជិត ត្រូវបានផុតរលត់។ ដូច្នេះ មិនមែនភាគីណាមួយអាចបង្ខំភាគីមួយទៀតឱ្យបន្តកិច្ចសន្យាទេ ប្រសិនបើគ្មានការព្រមព្រៀង* "។(*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១០០/០៧-ហូយៀ ខេមបូឌា ហេតុផលនៃសេចក្តីសម្រេច ចំណុចវិភាគទី២*)។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របទៅនឹងការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ។ ក្នុងករណីនេះ លោក ហួ រដ្ឋា បានចាប់ផ្តើមចូលធ្វើការដំបូងដែលមានការងារសាកល្បងចំនួន ២ ខែ។ បន្ទាប់មក និយោជកក៏បានបន្តកិច្ចសន្យា ដែលមានកំណត់ថិរវេលាចំនួន ៣ ខែបន្តទៀត ដោយគិតចាប់ពីថ្ងៃទី០៣ ខែឧសភា ដល់ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ។ ចំពោះកិច្ចសន្យាការងារចុងក្រោយនេះ និយោជកពុំបានបន្តជូនគាត់ទេ ដោយធ្វើការបញ្ចប់នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កិច្ចសន្យាដែលមានកំណត់ថិរវេលារបស់លោក ហួ រដ្ឋា ត្រូវផុតរលត់ ដូចនេះ កាតព្វកិច្ចរបស់ភាគីនិយោជក និងកម្មករនិយោជិតក៏ត្រូវបានផុតរលត់ដែរ ដូចនេះ ភាគីម្ខាងនៃកិច្ចសន្យា ពុំអាចបង្ខំឱ្យភាគីម្ខាងទៀតឱ្យបន្តកិច្ចសន្យាការងារជូនខ្លួន ឬទទួលយកចូលធ្វើការវិញបានទេ។

ប៉ុន្តែក្នុងករណីនេះ លោក ហួ រដ្ឋា បានជាប់ឆ្នោតជាប្រធានសហជីព។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបន្តពិចារណាការលើកឡើងនេះទៀត ៖

មាត្រា ២៩៣ កថាខណ្ឌ១ នៃច្បាប់ស្តីពីការងារចែងថា "*រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬ រាល់ការបញ្ឈប់បេក្ខជនណា ម្នាក់ពីការងាររបស់ខ្លួន អាចធ្វើបានលុះត្រាណាតែមានការយល់ព្រមពីអធិការការងារ ...*" ។

ប្រការ៣ កថាខណ្ឌទី៣ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ចែងថា " *កម្មករនិយោជិតទាំងអស់ដែលជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ទទួលបាននូវការការពារចំពោះការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ ...*" ។

យោងតាមមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារ និងប្រការ៣ នៃប្រកាសលេខ ៣០៥ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា រាល់ការបញ្ឈប់កម្មករនិយោជិតដែលទទួលបានការការពារ និយោជកចាំបាច់ត្រូវជូនដំណឹង និងមានការយល់ព្រមពីអធិការការងារជាមុនសិន។

ប៉ុន្តែនៅក្នុងសំណុំរឿងលេខ ១០/០៩-ញូ វ៉ាយដី ខេមបូឌា ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការមិនបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ចំពោះកម្មករនិយោជិតដែលទទួលបានការការពារពីការបញ្ឈប់ពីការងារមិនតម្រូវឱ្យមានការយល់ព្រមពីអធិការការងារនៅពេលបញ្ឈប់ពីការងារនោះទេ ព្រោះវាស្ថិតក្នុងស្ថានភាពកិច្ចសន្យាការងារផុតរលត់ ដែលមិនមែនជាការបញ្ឈប់ពីការងារទេ។

ដូចនេះ ការបញ្ចប់កិច្ចសន្យាការងាររបស់លោក ហួ រដ្ឋា ពុំចាំបាច់ឱ្យនិយោជកជូនដំណឹង និងមានការយល់ព្រមពីអធិការការងារទេ។

ក្នុងករណីនេះដែរ ភាគីកម្មករនិយោជិតបានលើកឡើងថា និយោជកបានបញ្ចប់កិច្ចសន្យាការងាររបស់លោក ហូ រដ្ឋា គឺដោយសារមានការរើសអើងសកម្មភាពសហជីព ព្រោះបន្ទាប់ពីនិយោជកដឹងថា លោក ហូ រដ្ឋា ជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពមក ។

ជាទូទៅ ទាក់ទងនឹងភស្តុតាងនៃការរើសអើងសហជីព ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើការឆ្លើយបំភ្លឺនៅក្នុងសវនាការ និងធ្វើការពិនិត្យទៅលើភស្តុតាងដែលពាក់ពន្ធ័ទៅនឹងសំណុំរឿងដើម្បីកំណត់ថា មានការរើសអើងសហជីពកើតមានឡើងដែរ ឬទេ ទាក់ទងនឹងការមិនបន្តកិច្ចសន្យាការងារដែលមានកំណត់ចិរវេលា ។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦៧/១០-ម៉េង យ៉ាន ហេតុផលចំណុចវិវាទទី២*) ។

នៅក្នុងសវនាការ ភាគីកម្មកនិយោជិតពុំបានបង្ហាញពីសកម្មភាពរបស់និយោជកទាក់ទងនឹងការរើសអើងសហជីពដោយរបៀបណាទេ ពោលគ្រាន់តែបញ្ជាក់ថា ការបញ្ចប់កិច្ចសន្យាការងារនេះ គឺដោយសារតែមានការរើសអើងសហជីព។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា មានកម្មករនិយោជិតមួយចំនួនធំ ដែលបានជាប់ឆ្នោតសម្រាប់អណត្តិទី៣ ដែលជាថ្នាក់ដឹកនាំសហជីព ជាទីប្រឹក្សាសហជីព និងជាសកម្មជនសហជីព ប៉ុន្តែ ពួកគាត់ទាំងនោះពុំត្រូវបាននិយោជកបញ្ចប់កិច្ចសន្យាការងារទេ លើកលែងតែកញ្ញា អេន សុខណា ដែលគាត់បានលាលែងពីការងារដោយខ្លួនឯង។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បើនិយោជកមានការរើសអើងសហជីពពិតប្រាកដមែន និយោជកប្រាកដជាធ្វើការបញ្ឈប់ ឬបញ្ចប់កិច្ចសន្យាការងាររបស់ពួកគាត់ទាំងនោះជាពុំខាន ។ ផ្ទុយទៅវិញ និយោជកបានបង្ហាញថា មូលហេតុដែលនិយោជកពុំព្រមបន្តកិច្ចសន្យាការងារជូនលោក ហូ រដ្ឋា ដោយសារតែរូបគាត់ផ្ទាល់ពុំសូវយកចិត្តទុកដាក់នឹងការងារ និងពុំសហការជាមួយក្រុមហ៊ុន ។ ហើយករណីនេះ លោក ហូ រដ្ឋា ក៏ពុំបានបដិសេធទៅនឹងការលើកឡើងរបស់និយោជកដែរ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតមិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីអាចបញ្ជាក់ថា ការមិនបន្តកិច្ចសន្យាលើកនេះ គឺដោយសារតែការចូលរួមជាប់ឆ្នោតជាបេក្ខជនសហជីពឡើយ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកទទួលយកលោក ហូ រដ្ឋា ជាថ្នាក់ដឹកនាំសហជីពចូលធ្វើការវិញ និងគិតប្រាក់រំលឹក ចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

**សម្រេច និង បង្គាប់**

ចំណុចវិវាទ ៖ បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកទទួលយកលោក ហូ រដ្ឋា ជាថ្នាក់ដឹកនាំសហជីពចូលធ្វើការវិញ និងគិតប្រាក់រំលឹកចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ ។

THE ARBITRATION COUNCIL

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ីខ សុទ្ធី**

ហត្ថលេខា: ---------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ទ៉ែន ពៅ**

ហត្ថលេខា: ---------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **រុន សាវ៉ិយ**

ហត្ថលេខា: ---------------------------------